# វិធីសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ជីកាកសំណល់ឡ

## ១.ការគ្រប់គ្រងជីកាកសំណាល់ឡត្រឹមត្រូវ



**ជួយ** សន្សំជីកំប៉ុស្តិ៍បានប្រមាណ **២០តោន/ឆ្នាំ**

**ជួយ** សន្សំថវិកាប្រមាណ **៥០ដុល្លា/ឆ្នាំ** ពីការទិញជីគីមី

**កសិករមិនចាំបាច់ចំណាយពេលវេលាច្រើនក្នុងការផលិតជី**

*ដើម្បីគ្រប់គ្រងជីបានល្អ កសិករត្រូវធ្វើដូចខាងក្រោម៖*













## ២.ការប្រើប្រាស់ជីកាកសំណាល់ឡ

### ប្រើសំរាប់ដំណាំគ្រប់ប្រភេទ



- ❖ ប្រើជីពីរោងជីកំប៉ុស្តិ៍សំរាប់ទ្រាប់បាត ឬបំប៉ន ប្រមាណ ១៥-២០តោន ក្នុងមួយហិកតា
- ❖ ប្រើជីរាវ ១ភាគ លាយទឹក ៣ភាគ ស្រោចបំប៉នពីលើ ឬនៅតាមចន្លោះរង
- ❖ ស្រោចទឹកបន្ថែមពីលើការពារកុំអោយរលាកស្លឹក ។

### ប្រើសំរាប់ចិញ្ចឹមត្រី



- ❖ **ធ្វើចំណីត្រី:** យកជីរាវ (៤០%) លាយ បបរចុងអង្ករ, ត្រកួន និងកន្ទក់ (៦០%) រួចដាក់ក្នុងល្អី ចងពន្លិចនៅកែងស្រះទឹក ។
- ❖ កសិករអាចលាយកាកសំណល់ឡជាមួយ ចំណីត្រីពី២០-៣០% ។
- ❖ **កែលំអទឹកបង្កើតបួងតុង:** យកជី ៥០-៦០គ.ក្រ លាយកំបោរ រស់ ៥គ.ក្រ

### ប្រើសំរាប់ចិញ្ចឹមជន្លេន



១. ជីករណ្តៅ និងក្រាលផ្លាស្ទិច (ប:២ម ទ:១,៥ម ជំរៅ ០,៣ម)

២. ប្រក់ដំបូលអោយជិត រួចដាក់ជីកាក សំណល់ ឡពាក់កណ្តាលស្ងួត ទៅក្នុង រណ្តៅកំរាស់ ២,៥តឹក បន្ទាប់មកដាក់ ពូជជន្លេនកប់ក្នុងជី

៣. អាចប្រមូលផល ចន្លោះ ២-៣ខែ ។ ចូកយកផ្នែកដែលមាន ជន្លេនច្រើន និងចាក់បំពេញកាកសំណល់ឡថ្មីភ្លាម ។

### ប្រើសំរាប់ផ្សំថ្នាំកំចាត់សត្វល្អិត



**ធាតុផ្សំ:** ស្លែង ស្លាក់ វល្លិ៍បណ្តូលពេជ្រ ស្តៅ ទៀបខ្មែរ ម្ទេស ថ្នាំជក់ គល់ស្លឹកគ្រៃ មើមក្តួច... ។ល ។

**របៀបផ្សំ:** ចិញ្ច្រាំធាតុផ្សំទាំងអស់ចូលគ្នា ដាក់ក្នុងពាងរួចចាក់ទឹកកាកសំណល់ (ច្រោះយកតែទឹក) និងត្រាំទុករយៈពេល ២-៣ សប្តាហ៍ទើបអាចយកមកប្រើបាន ។

**របៀបប្រើ:** យកទឹកថ្នាំ ១ភាគ លាយទឹកធម្មតា ៤ភាគ ស្រោចពីលើដំណាំនៅពេលព្រឹក ឬពេលល្ងាច ។

**កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ : ០២៣ ៩៩២ ៦០៩** ផ្លូវ៣៧១ សង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ ឬ កម្មវិធីឡជីវឧស្ម័ននៅតាមបណ្តាខេត្ត